CITY OF LONG BEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 26 ខែកុម្ភៈ ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សាលាក្រុងឡុងប៊ិច ដាក់ឱ្យដំណើរការ ទំព័រទិន្នន័យវ៉ាក់សាំង នៅលើគេហទំព័រទិន្នន័យ COVID-19 របស់ក្រុង ។

## *វ៉ាក់សាំង ជាង 104,000 ដូស ត្រូវបានចាក់ជូនប្រជាពលរដ្ឋ ដែលក្នុងនោះ 60% នៃមនុស្សវ័យចាស់ នៅឡុងប៊ិច បានទទួលវ៉ាក់សាំង យ៉ាងហោចណាស់ មួយដូស ។*

ឡុងប៊ិច, CA - ដោយចាប់ផ្តើម ពីថ្ងៃទី 26 ខែកុម្ភៈនេះទៅ នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស (នាយកដ្ឋានសុខាភិបាល) នៃសាលាក្រុងឡុងប៊ិច នឹងរួមបញ្ចូល ទំព័រទិន្នន័យវ៉ាក់សាំង នៅលើគេហទំព័រទិន្នន័យ COVID-19 លក្ខណៈអន្តរសកម្ម ដែលមានស្រាប់ របស់ក្រុង ដោយរំលេចទិន្នន័យចាក់វ៉ាក់សាំង COVID-19 តាមពេលវេលាជាក់ស្តែង សម្រាប់ឡុងប៊ិច ។ ទិន្នន័យរួមមាន សេចក្តីរាយបញ្ជាក់ អំពីចំនួនសរុប នៃប្រជាពលរដ្ឋចាក់វ៉ាក់សាំងរួច និងព័ត៌មានប្រជាសាស្ត្រលំអិត សម្រាប់ប្រជាពលរដ្ឋឡុងប៊ិច ដែលបានចាក់វ៉ាក់សាំងរួច ។

ចៅហ្វាយក្រុង រ៉ូប៊ឺត ហ្គាសៀ (Mayor Robert Garcia) «ខ្ញុំមានសេចក្តីរីករាយ ឥតឧបមា និងមានមោទកភាពណាស់ ដែល 60% នៃជនវ័យចាស់ ដែលមានអាយុ 65+ ឆ្នាំ របស់យើង បានចាក់វ៉ាក់សាំងរួច ។» «ខណៈដែលយើងបន្តចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋ ឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ជាការសំខាន់ ដែលយើងផ្សព្វផ្សាយទិន្នន័យការងារនេះ លក្ខណៈបើកទូលាយ ជូនសាធារណជន ។»

**ទិន្នន័យវ៉ាក់សាំង**
ទំព័រទិន្នន័យ COVID-19 ថ្មីដូចមានបង្ហាញជាប៊ុតុង នៅលើលើគេហទំព័រទិន្នន័យ COVID-19 លក្ខណៈអន្តរសកម្ម ដែលមានស្រាប់ របស់ក្រុងនេះ, រំលេចទិន្នន័យចាក់វ៉ាក់សាំង COVID-19 តាមពេលវេលាជាក់ស្តែង ដូចជា ចំនួនដូសវ៉ាក់សាំងសរុប ដែលបានចាក់ ជូនប្រជាពលរដ្ឋ ក្នុងក្រុង, ចំនួនដូសដំបូង និងដូសទីពីរ ដែលបានចាក់, កាលបរិច្ឆេទចាក់វ៉ាក់សាំង, ចំនួនប្រជាពលរដ្ឋឡុងប៊ិចសរុប ដែលបានចាក់វ៉ាក់សាំង, និង ព័ត៌មានប្រជាសាស្ត្រលំអិត អំពីប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំងរួច ដូចជា អាយុ ភេទ ជាតិពិន្ទុ/ជាតិសាសន៍ និងលេខកូដតំបន់ ។

សេចក្តីរំលេច អំពីទិន្នន័យបញ្ចេញផ្សាយ ថ្ងៃនេះ រួមមាន ៖

- វ៉ាក់សាំង ចំនួន 104,374 ដូស ត្រូវបានចាក់ជូន ប្រជាពលរដ្ឋឡុងប៊ិច ។
- មកទល់បច្ចុប្បន្ននេះ ប្រជាពលរដ្ឋឡុងប៊ិច ចំនួន 66,553 នាក់ បានចាក់វ៉ាក់សាំងរួច យ៉ាងហោចណាស់ បានមួយដូស ដែលមានកម្រិត ប្រមាណ 14.5% នៃប្រជាពលរដ្ឋក្រុងទាំងអស់ ធៀបទៅនឹង 12% នៃប្រជាពលរដ្ឋ នៅខោនធីឡូស អ៊ែនជឺឡេស និង 8.2% នៅខោនធីអូរ៉េង (Orange) ។

- 60% នៃប្រជាជនវ័យចាស់ នៅក្នុងទីក្រុង (អ្នកដែលមានអាយុ 65 ឆ្នាំ និងច្រើនជាងនេះ) បានចាក់វ៉ាក់សាំង នៅឡុងប៊ិច ឬ នៅទីតាំងផ្សេងទៀត ធៀបនឹង 43% នៃប្រជាជនវ័យចាស់ នៅខោនធីឡូស អ៊ែនជីឡេស និង 52.6% នៅខោនធីអូរ៉េង ។ សូមកត់សម្គាល់ថា 47.9% ដូចមានបង្ហាញ នៅលើគេហទំព័រ បង្ហាញពីចំនួនប្រជាពលរដ្ឋវ័យចាស់ នៅឡុងប៊ិច ដែលបានចាក់វ៉ាក់សាំងរួច ធៀបនឹង ភាគរយ នៃប្រជាពលរដ្ឋទាំងអស់ នៅក្នុងទីក្រុង ដែលបានចាក់វ៉ាក់សាំងរួច ។
- ទិន្នន័យលេខកូដតំបន់ បង្ហាញថា អត្រាចាក់វ៉ាក់សាំង មានចាប់ពី 7.9% ដល់ 24.1% នៃប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំងរួច ដែលបង្ហាញថាមាន សេចក្តីត្រូវការ ជាបន្ត ឱ្យមានការផ្សព្វផ្សាយ អំពីការចាក់វ៉ាក់សាំង និងអន្តរាគមន៍ នៅឡុងប៊ិច ប៉ែកខាតជើង កណ្តាល និងខាងលិច ដែលលក្ខណៈផ្តោតជាក់លាក់ ។
- ទិន្នន័យនេះបង្ហាញ ពីប្រជាពលរដ្ឋ ស្បែកស ដែលមានជិត 40% នៃប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំងរួច ត្រូវនឹង ទិន្នន័យជំរឿន ដែលបង្ហាញ ពីប្រជាពលរដ្ឋវ័យចាស់ របស់ឡុងប៊ិច ថាមាន 54% ជាប្រជាពលរដ្ឋ ស្បែកស ។

ទំព័រទិន្នន័យចាក់វ៉ាក់សាំងនេះ នឹងមានធ្វើបច្ចុប្បន្នភាព ជាទៀងទាត់ ជាមួយទិន្នន័យផ្សេងៗ ទៀត របស់គេហទំព័រ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ឬ នៅពេលមានទិន្នន័យថ្មីអាចប្រើប្រាស់បាន ។

**កិច្ចខិតខំប្រឹងប្រែងឈានទៅរកសហគមន៍ ប្រកបដោយសមធម៌**
សាលាក្រុងឡុងប៊ិច និងដៃគូ បានបើកដំណើរការ គ្លីនិកចាក់វ៉ាក់សាំង ចំនួនប្រាំកន្លែង នៅឡុងប៊ិច ប៉ែកខាងជើង ខាងលិច និងកណ្តាល កាលពីខែកុម្ភៈ ដើម្បីបម្រើសេវាជូន ដោយផ្ទាល់ នៅតាមតំបន់ ដែលទទួលរងផលប៉ះពាល់ ខ្លាំងបំផុត ពី COVID-19 ដើម្បីចូលឱ្យដល់ក្រុម ដែលត្រូវការធនធានវ៉ាក់សាំង ។ គ្លីនិក បន្ថែមទៀត នឹងត្រូវបានរៀបចំផែនការឡើង នៅខែមីនា ។ សប្តាហ៍នេះ សាលាក្រុងបានទទួលវ៉ាក់សាំង ដូសទីមួយ ចំនួន 5,100 បន្ថែមទៀត ដែលត្រូវបានកំណត់កាលវិភាគចាក់ជូនប្រជាពលរដ្ឋ ពីថ្ងៃពុធ ដល់ថ្ងៃសុក្រ ដោយផ្តោតលើ អ្នកចូលរួម VaxLB នៅតាមលេខកូដតំបន់ ដែលមានអត្រាករណី COVID-19 ខ្ពស់ និងអត្រាចាក់វ៉ាក់សាំង ទាប ។

**រចនាបថបញ្ច្រាប ទៅមូលដ្ឋាន**
ស្រដៀងគ្នា នឹងទំព័រទិន្នន័យ COVID-19 ផ្សេងទៀតដែរ, ទំព័រទិន្នន័យវ៉ាក់សាំង រំលេចពី អត្ថបទ និងរូបភាព លក្ខណៈសាមញ្ញ ដែលបានរៀបចំឡើង និងដាក់ជូនសាធារណជន ដោយគិតគូរ ពីអ្នកប្រើប្រាស់ចុងក្រោយ ។ ព័ត៌មាន ត្រូវបានចងក្រងឡើង ជាពិសេស សម្រាប់សាធារណជនទូទៅ ហេតុនេះអ្នកចូលមើល អាចរកបានព័ត៌មាន ដែលពួកគេត្រូវការ បានយ៉ាងរហ័ស និងដោយងាយស្រួល ។

ឃែលលី ខូឡូភី (Kelly Colopy) ប្រធាននាយកដ្ឋានសុខាភិបាល បានបញ្ជាក់ថា «យើងខ្ញុំបានធ្វើការប្រកបដោយការយកចិត្តទុកដាក់ ដើម្បីធានាថា ទិន្នន័យទាំងនេះ មានបង្ហាញជូន បានទាន់ពេលវេលា បានត្រឹមត្រូវ និងប្រកបដោយអនុលោមភាព ដែលសាធារណជន អាចងាយមើលយល់ ។» «យើងខ្ញុំនឹងបន្តផ្តល់ជូន ទិន្នន័យចាក់វ៉ាក់សាំង បន្ថែមទៀត នៅពេលមានទិន្នន័យអាចប្រើប្រាស់បាន ។»

សាលាក្រុងបានកំពុងធ្វើការងារចាក់វ៉ាក់សាំង ឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន សម្រាប់អ្នកស្ថិតនៅក្នុងក្រុម ដែលអាចចាក់វ៉ាក់សាំងបាន នៅពេលមានវ៉ាក់សាំងមកដល់ ។ កាលពីខែធ្នូ ឆ្នាំ 2020 សាលាក្រុងបានប្រកាស ពីផែនការចាក់វ៉ាក់សាំង ប្រកបដោយសមធម៌ ហើយតាំងពីពេលនោះមក បានចាប់ផ្តើមចាក់វ៉ាក់សាំង ជូនមន្ត្រីសុខាភិបាល, ជនវ័យចាស់, បុគ្គលិកសេវាសង្គ្រោះបន្ទាន់, មន្ត្រីអប់រំ និងនិយោជិតវិស័យចំណីអាហារ នៅឡុងប៊ិច ។

CITY OF LONG BEACH

# PRESS RELEASE

ពីដើមឡើយ សាលាក្រុងបានដាក់ឱ្យដំណើរការ គេហទំព័រទិន្នន័យ COVID-19 កាលពីខែមេសាមុន ហើយតាំងពីពេលនោះមក យើងមានទិន្នន័យ កាន់តែច្រើនឡើង ។

គិតត្រឹមថ្ងៃទី 25 ខែកុម្ភៈ មានករណី COVID-19 ចំនួន 51,195 នៅឡុងប៊ិច និង អ្នកជំងឺ 832 នាក់ បានបាត់បង់ជីវិត ដោយសារវីរុសនេះ ។ វ៉ាក់សាំង ជាង 104,300 ដូស ត្រូវបានចាក់ជូន ប្រជាពលរដ្ឋ ដែលក្នុងនោះ ចំនួន 66,500 ជាង ជាដូសទីមួយ និង ជាង 37,800 ជាដូសទីពីរ ។ ចំនួនទាំងនេះ ខុសគ្នា ពីចំនួនប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំងរួច ខាងលើនេះ ដោយមនុស្សជាច្រើន នៅឡុងប៊ិច បម្រើការងារ នៅក្រៅក្រុង ហើយបានចាក់វ៉ាក់សាំង តាមរយៈនិយោជករបស់ពួកគេ ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #